មជ្ឈមណ្ឌលឯកសារកម្ពុជា

# វ៉ាន់ ណាត : សាក្សីប្រវត្តិសាស្ត្រ

**ឆាំង យុ**

**ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១១**

*ប្រែសម្រួលដោយ*

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១១ នេះ លោក វ៉ាន់ ណាត បានលាចាកលោកចោលយើងទាំងអស់គ្នាជារៀងរហូតហើយ ។ ក្នុងនាមជាអ្នករស់រានមានជីវិតម្នាក់ក្នុងចំណោមអ្នកទោសប្រមាណត្រឹមតែដប់បួនរូបប៉ុណ្ណោះដែលរួចផុតពីការកាប់សម្លាប់នៅគុកទួលស្លែង លោក វ៉ាន់ ណាត គឺជាសាក្សីប្រវត្តិសាស្ត្រដ៏សំខាន់ម្នាក់ ។ លោក វ៉ាន់ ណាត បានបង្ហាញនូវកម្លាំងកាយនិងចិត្តយ៉ាងមាំមួន ដើម្បីផ្តល់សក្ខីកម្មប្រវត្តិសាស្ត្រ ទោះបីជាលោកបានទទួលរងនូវ អំពើឧក្រិដ្ឋដ៏ខ្លោចផ្សា និងទោះបីជាឋិតក្នុងស្ថានភាពមួយ ដែលអ្នកធ្លាប់ធ្វើបាបលោក កំពុងតែរីករាយរស់នៅក្នុងនិទ្ទណ្ឌភាពអស់រយៈពេលជាងសាមសិបឆ្នាំយ៉ាងណាក៏ដោយ ។ នៅពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានបង្កើតឡើង ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះរាប់លាននាក់ក្រោមរបបខ្មែរក្រហម លោក វ៉ាន់ ណាត បានសម្រេចចិត្តមិនដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទេ ។ លោក វ៉ាន់ ណាត បានជ្រើសយកជម្រើសបែបនេះ ដោយលោកយល់ថា ភារកិច្ចដ៏ចម្បងរបស់លោក គឺត្រូវផ្តល់សក្ខីកម្មសម្រាប់ក្មេងៗកម្ពុជាជំនាន់ក្រោយដើម្បីរៀនសូត្រពីប្រវត្តិសាស្ត្រ ។ ជម្រើសរបស់លោក វ៉ាន់ ណាត ឆ្លុះបញ្ចាំងឲ្យឃើញទស្សនៈយុត្តិធម៌ ដែលសំដៅទៅលើអនាគតមនុស្សជាតិ ជាជាងក្តីបំណងដែលមានលក្ខណៈបុគ្គល និងមិនសូវឋិតថេរយូរអង្វែងដើម្បីទាមទារឲ្យមាន ការដាក់ទោសទណ្ឌ ការសងសឹក ឬសំណងផ្សេងៗ ។

ការបាត់បង់លោក វ៉ាន់ ណាត មុនពេលអ្នកឯទៀតដែលទទួលខុសត្រូវក្នុងការបង្កើតគុកទួលស្លែងឬមន្ទីរស-២១ ត្រូវបានវិនិច្ឆ័យទោស គឺជាសោកនាដកម្មមួយដែលបង្ហាញឲ្យឃើញនូវ តម្លៃមិនអាចកាត់ថ្លៃបានចំពោះពេលវេលាដែលអាច និងបន្តឲ្យមានផលប៉ះពាល់ដល់ដំណើរស្វែងរកយុត្តិធម៌ ។ ដោយក្តីក្រៀមក្រំ សោកនាដកម្មនៃមរណភាពរបស់លោក វ៉ាន់ ណាត នៅតែបន្តកើតមានយ៉ាងស្ងៀមស្ងាត់ម្តងទៀតទូទាំងផ្ទៃប្រទេសកម្ពុជា ដោយសារតែពីមួយថ្ងៃទៅមួយថ្ងៃ ជនរងគ្រោះនៃរបបខ្មែរក្រហមចេះតែបាត់បង់ទៅៗ ដោយគ្មានបានផ្តល់ជូននូវយុត្តិធម៌ណាមួយ ដល់ជនរងគ្រោះទាំងនោះទាល់តែសោះ ។ អ្វីដែលជាសោកនាដកម្មធំជាងនោះទៅទៀតនោះគឺថា មរណភាពមួយចំនួនអាចនឹងធ្វើការទប់ស្កាត់បានប្រសិនបើប្រជាជនកម្ពុជាជាទូទៅអាចស្វែងរកសេវាថែទាំសុខភាពទំនើបបាន ។ នេះធ្វើ

ឲ្យឃើញថា សេវាថែទាំសុខភាពលំដាប់ពិភពលោកដែលបានផ្តល់ឲ្យមេដឹកនាំខ្មែរក្រហមនៅឯតុលាការខ្មែរក្រហម មើលទៅហាក់បីដូចជាមិនស្មើភាពចំពោះជនរងគ្រោះសោះឡើយ ។ វាមានការលំបាកក្នុងការពន្យល់ឲ្យបានល្អអំពីគោលដៅដ៏ជាក់លាក់ណាមួយ ដូចជាការលើកកម្ពស់” នីតិរដ្ឋ ចំពោះជនរងគ្រោះដែលមិនមានលទ្ធភាពសូម្បីតែឲ្យគ្រូពេទ្យពិនិត្យសុខភាពធម្មតាផង ។

ទោះជាយ៉ាងនេះក្តី តាមរយៈការផ្តល់សេវាថែទាំសុខភាព ដល់មេដឹកនាំខ្មែរក្រហមដោយធ្វើតាមបទដ្ឋានតុលាការយុត្តិធម៌ និងគោលការណ៍សិទ្ធិមនុស្ស តុលាការខ្មែរក្រហមអាចផ្តល់នូវអ្វីមួយផ្សេងទៀត ដើម្បីជាសមានចិត្តដល់លោក វ៉ាន់ ណាត និងអ្នកដទៃទៀតដែលធ្លាប់បានទទួលរងការឈឺចាប់នៅគុកទួលស្លែងនិងគុកខ្មែរក្រហមដទៃទៀតទូទាំងប្រទេសដូចជា ភាពព្រៃផ្សៃ អំពើទារុណកម្ម និងការអាប់ឱនយសស័ក្តិនិងភាពថ្លៃថ្នូរជាមនុស្ស ។ ទោះបីជាការការពារសិទ្ធិរបស់មេដឹកនាំខ្មែរក្រហមជួនកាលអាចជាគ្រាប់ថ្នាំល្វីងដូចគ្រាប់ស្លែងដែលលំបាកក្នុងការលេបយ៉ាងណាក៏ដោយ សូម្បីតែមានការលំបាកទទួលយកនូវការមិនពេញចិត្តពីសំណាក់ជនរងគ្រោះ ក៏ការធ្វើបែបនេះ បានផ្តល់មេរៀនមួយសម្រាប់អនាគតដែលធ្វើឲ្យលោក វ៉ាន់ ណាត មានមោទកភាពដែលត្រង់ថា រាល់ប្រជាជនទាំងអស់សុទ្ធតែមានសិទ្ធិក្នុងការទទួលបាននូវសេចក្តីថ្លៃថ្នូរនិងភាពស្មើគ្នាចំពោះមុខច្បាប់ ។

លោក វ៉ាន់ ណាត គឺជាមិត្តរបស់យើងទាំងអស់គ្នា ហើយការចាកចេញដ៏សែនឆ្ងាយរបស់លោកធ្វើឲ្យយើងទាំងអស់គ្នានៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានក្តីនឹករឭកយ៉ាងពន់ពេក ហើយអ្នកផ្សេងទៀតនៅក្នុងពិភពលោកក៏នឹងមានការនឹករឭកដល់រូបលោកដែរ ។ យើងទាំងអស់គ្នានឹងនឹករឭកដល់លោកជានិច្ច ហើយចេញពីទង្វើ និងទឹកចិត្តដែលលោកបានធ្វើជំរុញយើងឲ្យនឹកគិតដល់សន្តិភាពផ្លូវចិត្តដែលបានសម្តែងចេញពីទឹកចិត្តរបស់លោក ។

**-ចប់-**